**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Sep-2014, 14:59
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**: ជាមួយ ឧបសម្ព័ន្ធ**សម្ងាត់** ៣

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/**Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**បញ្ជីឯកសារបន្ថែមសម្រាប់សវនាការ របស់សហព្រះរាជអាជ្ញា**
**អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

១- សហព្រះរាជអាជ្ញាសូមដាក់ជូនឯកសារបន្ថែម ទៅនឹងបញ្ជីឯកសាររបស់ខ្លួនសម្រាប់សំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤[1]។ នៅក្នុងឧបសម្ព័ន្ធចំនួនបីអមជាមួយនឹងការដាក់ឯកសារនេះ សហព្រះរាជអាជ្ញាកំណត់អត្តសញ្ញាណ៖ ឯកសារបន្ថែមចំនួន១៦ ដែលបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ រួចហើយ (ឧបសម្ព័ន្ធ **D1**), ឯកសារបន្ថែមចំនួន១០១ ដែលមាននៅក្នុងសំណុំរឿង០០២រួចហើយ ប៉ុន្តែមិនទាន់បានទទួលយកជាភស្តុតាងនៅឡើយ (ឧបសម្ព័ន្ធ **D2**), និងឯកសារបន្ថែមចំនួន២៦ ដែលមិនមាននៅក្នុងសំណុំរឿង០០២ (ឧបសម្ព័ន្ធ **D3**), ដែលខ្លួនបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០២។ ឯកសារទាំងនេះជាបឋមមានកំណត់ហេតុ (មាន៖ បទសម្ភាសន៍ ពាក្យសុំចូលជាដើមបណ្តឹងរដ្ឋប្បវេណី ពាក្យបណ្តឹង) ឬឯកសារភស្តុតាងដទៃទៀតដែលពាក់ព័ន្ធនឹងបុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មក្នុងសវនាការសំណុំរឿង០០២/០២ និងភស្តុតាងបន្ថែមផ្សេងៗទៀត ដែលបានរកឃើញក្នុងពេលកំពុងរៀបចំរបស់សហព្រះរាជអាជ្ញា សម្រាប់ការចាប់ផ្តើមដំណើរការនីតិវិធីលើភស្តុតាងក្នុងសំណុំរឿង០០២/០២។

២- ឧបសម្ព័ន្ធ **D1** មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៦ ការដាក់ឯកសារសម្រាប់ផ្តល់ព័ត៌មានបន្ថែម ឬកំណត់ហេតុផ្សេងៗទៀត ដែលបានទទួលយកជាភស្តុតាងរួចហើយក្នុងសំណុំរឿង០០២ ប៉ុន្តែមិនទាន់បានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា កាលពីខែមេសា ឆ្នាំ២០១១ ឬកាលពីខែមិថុនា ឆ្នាំ២០១៤ អនុលោមតាមវិធាន៨០(៣) នៅឡើយទេ។ ឧបសម្ព័ន្ធ **D1** បន្ថែមលើឧបសម្ព័ន្ធ **B** ដែលស្រង់ចេញពីបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា កាលពីខែមិថុនា ឆ្នាំ២០១៤ អនុលោមតាមវិធាន៨០(៣)[2] និងបានដាក់ជូនស្របតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានស្នើថា បញ្ជីបច្ចុប្បន្នភាពរបស់ភាគីអនុលោមតាមវិធាន៨០(៣) រួមមានឯកសារដែលបានទទួលយករួចហើយ ដែលភាគីមានបំណងពឹងផ្អែក នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២[3]។ ដូចដែរឯកសារទាំងនោះបានទទួល

[1] **E305/13** បញ្ជីឯកសារសវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង, ១៣ មិថុនា ២០១៤។

[2] **E392.5** អនុស្សរណៈមានចំណងជើងថា៖ ការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីសម្រាប់កោះហៅឡើងវិញនូវសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ពីក្នុងសំណុំរឿង០០២/០១ មកក្នុងសំណុំរឿង០០២/០២, ៧ កុម្ភៈ ២០១៤។

[3] **E305** ដីកាបង្គាប់ឱ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង០០២/០២, ៨ មេសា ២០១៤, កំណត់សម្គាល់ជើងទំព័រលេខ១២។ **E305/2** សេចក្តីសម្រេចលើសំណើរួមទាក់ទងនឹងការដាក់ឡើងវិញ នូវភស្តុតាងដែលបានទទួលយករួចហើយសម្រាប់ប្រើប្រាស់នៅក្នុងសំណុំរឿង០០២/០២, ២១ ឧសភា ២០១៤, កថាខណ្ឌ៩។

យករួចហើយក្នុងសំណុំរឿង០០២[4] ឯកសារទាំងនោះមិនឆ្លើយតបទៅនឹងយុត្តិកម្ម តាមវិធាន៨៧(៤)ទេ[5]។

៣- ឧបសម្ព័ន្ធ **D2** មានឯកសារចំនួន១០១ដែលបានទទួលយករួចហើយក្នុងសំណុំរឿង០០២ ដែលពីមុនមក សហព្រះរាជអាជ្ញាមិនទាន់បានដាក់ ឱ្យទទួលយក នៅក្នុងបញ្ជីឯកសាររបស់ខ្លួន កាលពីឆ្នាំ២០១១ ឬកាលពីឆ្នាំ២០១៤ ដោយអនុលោមតាមវិធាន៨០(៣) ហើយមានបន្ថែមឧបសម្ព័ន្ធ **C1** ដែលដកស្រង់ចេញពីការដាក់ឯកសាររបស់សហព្រះរាជអាជ្ញា កាលពីខែមិថុនា ឆ្នាំ២០១៤[6]។ ឧបសម្ព័ន្ធនេះមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤២ ឬកំណត់ហេតុបន្ថែមជាច្រើន និងមានពាក្យបណ្តឹងចំនួន៣១។ ទាំងអស់ ឬភាគច្រើននៃឯកសារទាំងនេះជឿថា បានរួមបញ្ចូលកាលពីមុនរួចហើយ ក្នុងបញ្ជីឯកសាររបស់សហមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០(៣)នៃវិធានផ្ទៃក្នុង ប៉ុន្តែឯកសារទាំងនោះបានកំណត់អត្តសញ្ញាណជាក់លាក់នៅទីនេះហើយ ដែលសហព្រះរាជអាជ្ញាអាចប្រើភ្ជាប់ជាមួយនឹងបុគ្គលដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្ម ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង០០២/០២។ ជាងនេះទៀត នៅក្នុងសំណើសុំរួមដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា និងមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានសន្និដ្ឋានថា វិធាន៨៧(៤)នៃវិធានផ្ទៃក្នុង មិនគួរអនុវត្តចំពោះឯកសារដែលមាននៅក្នុងសំណុំរឿង០០២ឡើយ[7]។ ដូចនេះ សហព្រះរាជអាជ្ញានឹងពន្យារការដាក់សំណើស្របតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងសិន ដោយរង់ចាំមានសេចក្តីសម្រេចលើសំណើសុំនេះជាមុនសិន។ ដូចនេះ សហព្រះរាជអាជ្ញាអាចដាក់សំណើរួមមួយដែលពាក់ព័ន្ធនឹងឯកសារថ្មីទាំងអស់ ក្នុងនោះវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងអនុវត្តស្របតាមការណែនាំរបស់អង្គជំនុំជម្រះ[8]។

---

[4] **E392.5** អនុស្សរណៈមានចំណងជើងថា៖ ការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីសម្រាប់កោះហៅឡើងវិញនូវសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ពីក្នុងសំណុំរឿង០០២/០១ មកក្នុងសំណុំរឿង០០២/០២, ៧ កុម្ភៈ ២០១៤, កថាខណ្ឌ៧។

[5] **E305** ដីកាបង្គាប់ឱ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង០០២/០២, ៨ មេសា ២០១៤, កថាខណ្ឌ១៤។

[6] **E305/13.22** ឧបសម្ព័ន្ធ **C1**- ឯកសារដែលមាននៅក្នុងសំណុំរឿង០០២, ១៣ មិថុនា ២០១៤។

[7] **E307/1/1** សំណើសុំរួម ការសម្រេចឡើងវិញស្តីពីការអនុវត្តវិធាន៨៧(៤) ក្នុងសំណុំរឿង០០២/០២ និងសេចក្តីសន្និដ្ឋានទាក់ទងនឹងភាពមិនអាចអនុវត្តបាននៃវិធាន៨៧(៤) ចំពោះសម្ភារៈដែលមាននៅក្នុងសំណុំរឿងរួចហើយ, ១៥ សីហា ២០១៤, កថាខណ្ឌ ១៦-២១។

[8] *សូមអាន* **E307/3/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រ ដើម្បីធ្វើយុត្តិកម្មអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង", ២១ កក្កដា ២០១៤

៤- ឧបសម្ព័ន្ធ **D3** មានឯកសារថ្មីចំនួន២៦ ដែលមិនមាននៅក្នុងសំណុំរឿង០០២ ដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យមានការទទួលយក។ ឧបសម្ព័ន្ធនេះមានទស្សនាវដ្តីផ្សព្វផ្សាយរបស់ បកក ចំនួន១០ ដែលបានទទួលថ្មីពីមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងខែកក្កដា ឆ្នាំ២០១៤ ឯកសារមួយចំនួនទៀតដូចជា ការបោះពុម្ពផ្សាយពេលថ្មី បទសម្ភាសន៍ និងរបាយការណ៍សារព័ត៌មាន ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ និងភស្តុតាងមួយចំនួនទៀតដែលសហព្រះរាជអាជ្ញាបានរកឃើញចាប់តាំងពីពេលដាក់បញ្ជីឯកសាររបស់ខ្លួនកាលពីខែមិថុនា ឆ្នាំ២០១៤។ សហព្រះរាជអាជ្ញានឹងអនុវត្តយុត្តិកម្មពាក់ព័ន្ធនឹងវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង សម្រាប់ឯកសារទាំងនេះ នៅក្នុងសំណើរួមរបស់ខ្លួនជាបន្តបន្ទាប់ ហើយសហព្រះរាជអាជ្ញានឹងដាក់ឯកសារទាំងនោះក្នុងឃ្លាំងផ្ទុកឯកសាររួម ដូចដែលធ្លាប់បានធ្វើសម្រាប់ឯកសារដែលចុះក្នុងបញ្ជីក្នុងឧបសម្ព័ន្ធ **C2**[9]។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |

---

កថាខណ្ឌ ២ ("ដើម្បីជាផលប្រយោជន៍យុត្តិធម៌ ព្រមទាំងដើម្បីប្រសិទ្ធភាពផ្នែកនីតិវិធី និងការរៀបចំ ភាគីនីមួយៗអាចដាក់សារណារួមតែមួយ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង")។

[9] **E305/13.23** ឧបសម្ព័ន្ធ **C2** - ឯកសារដែលមិនមាននៅក្នុងសំណុំរឿង០០២, ១៣ មិថុនា ២០១៤។